សេចក្តីប្រកាសអំពីការរៀនតាមរយៈ អនឡាញ និង ភាពសម្ងាត់ផ្ទាល់ខ្លួន

ដើម្បីបញ្ជាក់ថា កិច្ចការរៀនរួមថ្នាក់ជាក្រុមតាមរយៈ អនឡាញ ឬ ការបង្ហាត់មេរៀនបង្ហាញភ្លាមៗ ពិតជានាំប្រយោជន៍ទៅកាន់ស្នាដៃ និង ការរៀនរបស់សិស្សមែន ក៏ក្រសួងអប់រំ ឡុងប៊ិច បានចែកផ្តល់គ្រូបង្រៀនជាជំនួយបច្ចេកទេសម្យ៉ាងហៅ Blocksi ។

Blocksi គឺជាការគ្រប់គ្រងមកលើ Chrome browser ដែលផ្តល់ការអនុញ្ញាតិសម្រាប់គ្រូបង្រៀនគន់មើលអំពី Chrome browser របស់សិស្ស នៅពេលណាសិស្សបើក អ៊ីម៉ែល ឡុងប៊ិច របស់គេ ។ គ្មានការបំពានអ្វីទេទៅកាន់ភាពសម្ងាត់ផ្ទាល់ខ្លួន ប៉ុន្តែ ជំនួយថ្មីនេះនឹងគាំទ្រមកលើកម្មវិធីរៀនពីចម្ងាយ ដោយផ្តល់ការអនុញ្ញាតិសម្រាប់គ្រូបង្រៀនធ្វើបានដូចតទៅ:

- ចែករំលែក គេហទំព័រ និង ជំនួយ អនឡាញ ផ្សេងៗទៅកាន់សិស្ស
- ឃ្លាំមើលភាពលូតលាស់របស់សិស្ស
- ជួយសិស្សបំពេញកិច្ចការតាមក្បួនបច្ចេកទេស
- គាំទ្រទៅកាន់សិស្សទាំងឡាយណា ដែលកំពុងជួបបញ្ហា
- សង្កត់ជួយសិស្សអោយយកចិត្តទុកដាក់មកលើមេរៀនចាំបាច់នៅតាមថ្នាក់
- ផ្តល់ឱកាសសម្រាប់សិស្សម្នាក់ៗបង្ហាញជាយោបល់

Blocksi គឺប្រើបានស្របកិច្ចយល់ព្រមផ្នែករក្សាពត៌មានជាភាពសម្ងាត់ផ្ទាល់ខ្លួនរបស់សិស្ស ហៅ California Student Data Privacy Agreement ។ ដើម្បីគ្រូបង្រៀនអាចប្រើ Blocksi បាន គឺត្រូវការអោយមានសិស្សបើកចូលសិនទៅក្នុង ក្រុមប៊ុគ ឡុងប៊ិច ដោយវាយបញ្ចូលលេខ អាយឌី និង password របស់គេ ឬ បើកចូលសិនទៅក្នុង ក្រុមប៊ុគ/ឡេបថប ផ្ទាល់ខ្លួន ដោយប្រើជាមួយ អ៊ីម៉ែល ឡុងប៊ិច (StudentID@student.lbschools.net) របស់គេ ។ **Blocksi គ្មានផ្តល់ការអនុញ្ញាតិអ្វីទេសម្រាប់បើកមើលអំពី browsers, applications ឬ desktops ផ្ទាល់ខ្លួនរបស់សិស្ស** ។ Blocksi អាចប្រើបានទៅតាមការសម្រេចយល់ឃើញពីគ្រូបង្រៀន និង តែនៅក្នុងពេលថ្ងៃបង្ហាត់មេរៀនប៉ុណ្ណោះ ។